**សុន្ទរកថាស្វាគមន៍**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារឆ្នាំ២០២០**

ថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០

- *សូមគោរព* ***ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ*** *រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់* ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** *ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ តំណាងដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ សមាគម និងតំណាងវិស័យឯកជន*
- *ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃបណ្តាអង្គភាពក្រោមឱវាទក្រសួង និងសមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ជាទីរាប់អាន និងជាទីមេត្រី!*

ថ្ងៃនេះ រូបខ្ញុំបាទ រួមនិងថ្នាក់ដឹកនាំក្រសួង ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពិតជាមានកិត្តិយសធំធេង និងក្តីសោមនស្សក្រៃលែង ដោយបានធ្វើគារវកិច្ចទទួលស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ** និង**ជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ក្នុងនាមតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹក អញ្ជើញជា**អធិបតី**ដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្មឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារឆ្នាំ២០២០ ដ៏នក្ខត្តឫក្ស នាព្រឹកនេះ។

នេះជាលើកទីពីរហើយ ក្នុងចន្លោះពេលបីឆ្នាំ ដែល **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** បានផ្តល់កិត្តិយស អញ្ជើញមកទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីបានជួបសំណេះសំណាលជាមួយមន្ត្រីរាជការក្រោមឱវាទក្រសួង ដែលកំពុងមានវត្តមាននៅទីនេះ ក្នុងមុខតំណែងចាប់ពីថ្នាក់ប្រធានការិយាល័យនៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ឡើងទៅ។ លើសពីនេះ

វេទិកានៃអង្គសន្និបាត ក៏បានផ្តល់ឱកាសជូនដល់តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាអង្គការ សមាគម ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ រួមទាំងតំណាងវិស័យឯកជន បានជួប និងបានត្រងត្រាប់ស្តាប់ដោយផ្ទាល់ នូវអនុសាសន៍ណែនាំជាគន្លឹះរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាទុនដ៏មានតម្លៃសម្រាប់ការដាក់ចេញជាទិសដៅភារកិច្ច និងការចាត់តាំងអនុវត្តនាពេលបន្ទាប់។ វត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** គឺជាសក្ខីភាពនៃការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល ចំពោះយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏ដូចជាវិស័យពាក់ព័ន្ធដទៃទៀត ទាំងផ្នែករដ្ឋ និងផ្នែកឯកជន ដែលកំពុងចូលរួមអនុវត្តយ៉ាងសកម្ម នូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមម្លប់សន្តិភាពដ៏ត្រជាក់ត្រជុំ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ជាទីគោរព ស្រឡាញ់យ៉ាងជ្រាលជ្រៅរបស់ប្រជាជនកម្ពុជា។

ខ្ញុំបាទសូមជម្រាបជូនថា តាមកម្មវិធីដែលបានគ្រោងទុក សន្និបាតនឹងដំណើរការទៅរយៈពេល ៣ ថ្ងៃកន្លះ គិតចាប់ពីថ្ងៃទី១៧ ខែកុម្ភៈ នេះ រហូតដល់ព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ដោយក្នុងនោះ បានរក្សាកម្មវិធីមួយថ្ងៃពេញ នៅថ្ងៃទី១៩ ខែកុម្ភៈ សម្រាប់ការស្តាប់បទបង្ហាញរបស់ថ្នាក់ដឹកនាំ និងបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញ ដែលចាត់ទុកជាថ្នាក់រៀនមួយ សម្រាប់ការបំពាក់បំប៉នចំណេះដឹងជូនដល់មន្ត្រីរាជការលើវិស័យជំនាញ បច្ចេកទេស ដែលចាំបាច់ត្រូវសិក្សារៀនសូត្រជាប្រចាំ។ សម្រាប់ព្រឹកថ្ងៃទី២០ ខែកុម្ភៈ ជាកម្មវិធីបូកសរុប បិទសន្និបាត និងឆ្លើយតបសំណួមពរនានារបស់អង្គសន្និបាត។

ខ្ញុំបាទ សូមយកឱកាសនេះ ថ្លែងនូវការអរគុណចំពោះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធ រួមទាំងតំណាងមកពីដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ អង្គការ សមាគម ស្ថាប័ននានាមកពីវិស័យឯកជន ដែលបានឆ្លើយតប និងអញ្ជើញមកចូលរួមនាពេលនេះ ញាំងឱ្យអង្គសន្និបាតប្រព្រឹត្តទៅយ៉ាងឧឡារឹក។ ការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ក្នុងអង្គសន្និបាតរបស់ក្រសួង គឺជាកាយវិការដ៏ប្រពៃ បង្ហាញពីការផ្សារភ្ជាប់ចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការល្អក្នុងភាពជាដៃគូ ជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីរួមគ្នាបន្តធ្វើដំណើរនៅលើមាគ៌ានៃសុខសន្តិភាព ការអភិវឌ្ឍ និងវិបុលភាព។ ខ្ញុំបាទសូមបញ្ជាក់ជូនគណៈអធិបតី និងភ្ញៀវចូលរួម បានជ្រាបថា សន្និបាតមានក្រុមការងារ ដើម្បីកត់ត្រា និងបូកសរុបរាល់មតិយោបល់ទាំងឡាយ ដែលឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ចូលរួមថ្លែងនូវបទអន្តរាគមន៍ ឬលើកជាចំណាប់អារម្មណ៍ និងសំណូមពរផ្សេងៗ ដែលឯកសារនេះ នឹងក្លាយជាធាតុចូលដ៏សំខាន់សម្រាប់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយត្រូវចងក្រងធ្វើជាឯកសារសំយោគ និងឯកសារយោងសម្រាប់អង្គសន្និបាត។ ហេតុដូច្នេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សង្ឃឹមថា វាគ្មិនទាំងអស់ នឹងជួយចែករំលែកនូវបទពិសោធន៍ល្អៗ, ចំណុចខ្លាំង, ខ្សោយ, បញ្ហាប្រឈម, ចំណុចជាវិធានការគន្លឹះ ជាជំនួយស្មារតីសម្រាប់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដកស្រង់រៀនសូត្រ កែលម្អ និងធ្វើការកែទម្រង់នៅពេលខាងមុខ សំដៅឆ្លើយតប និងអនុវត្តឱ្យបានសម្រេចនូវសូចនាករសំខាន់ៗនៃ «**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥**» និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងអាណត្តិទី៦ នៃរដ្ឋសភា។

- ***ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!***
- *ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!*

ជាមួយនឹងការជួបជុំប្រារព្ធសន្និបាតរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីបូកសរុប និងឆ្លុះបញ្ចាំងអំពីលទ្ធផលការងារក្នុងរយៈពេលមួយឆ្នាំកន្លងទៅ, ក្រសួងក៏កំពុងស្ថិតក្នុងរបត់មួយនៃការកែទម្រង់ស្ថាប័ន ដែលមានលក្ខណៈស៊ីជម្រៅជាងពេលមុនៗ ដោយសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅថ្មីៗនេះ បានសម្រេចអនុម័តលើសេចក្តីព្រាងច្បាប់ ស្តីពីការបង្កើតក្រសួងថ្មីលើមូលដ្ឋាននៃក្រសួងឧស្សាហកម្ម និងសិប្បកម្មបច្ចុប្បន្ន គឺ ***ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*** *[Ministry of Industry Science Technology and Innovation (MISTI)].*

ជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងជំហាននៃកំណែទម្រង់ថ្មីនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលនឹងក្លាយទៅជា***ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*** នឹងត្រូវបំពេញកិច្ចការដ៏មមាញឹកជាច្រើនថែមទៀត ដោយក្នុងនោះ ការងារដែលមានលក្ខណៈជាអាទិភាព និងបន្ទាន់ជាងគេ គឺ (១)ការដាក់ឆ្លងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅស្ថាប័នរដ្ឋសភាជាតិ និងព្រឹទ្ធសភា និងឆ្លងកាត់ពិនិត្យធម្មនុញ្ញភាពទៅក្រុមប្រឹក្សាធម្មនុញ្ញ (២)ការពិនិត្យកែសម្រួលបន្ថែម និងគោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(MISTI) (៣)ត្រូវរៀបចំក្បាលម៉ាស៊ីនដឹកនាំក្រសួងឡើងវិញ តាមនីតិវិធី (៤) ត្រូវរៀបចំរចនាសម្ព័ន្ធការងារ និងមុខតំណែងមន្ត្រី សម្រាប់អង្គភាពថ្មីពីរ ថ្នាក់អគ្គនាយកដ្ឋាន ចំណុះក្រសួងថ្មី (៥)ត្រូវរៀបចំផ្លាស់ប្តូរឈ្មោះ និងរៀបចំមន្ត្រីថ្នាក់ប្រធានមន្ទីរតាមមន្ទីររាជធានី ខេត្តឡើងវិញឱ្យស្របតាមច្បាប់បង្កើតក្រសួងថ្មី (៦)ពិនិត្យ និងរៀបចំធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តនានាដែលចាំបាច់ត្រូវធ្វើចំពោះមុខ ដើម្បីជានាភាពអនុលោមតាមច្បាប់ស្តីពីការបង្កើតក្រសួងថ្មី រួមទាំងកិច្ចការចាំបាច់មួយចំនួនទៀត។

ខ្ញុំបាទសូមយកឱកាសនេះ សូមគោរពសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលមានចក្ខុវិស័យដ៏ទូលំទូលាយ និងយូរអង្វែង និងបានអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្តូរឈ្មោះទៅជា ***ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*** ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា ស្របទៅតាមបរិបទនៃបច្ចេកវិទ្យា វិទ្យាសាស្ត្រ ក៏ដូចជារបកគំហើញ ដែលកំពុងវិវត្តន៍ទៅយ៉ាងឆាប់រហ័ស មានជាលក្ខណៈសកល និងដើម្បីធ្វើឱ្យផ្នែកស្រាវជ្រាវលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងរបកគំហើញផ្សេងៗ (នវានុវត្តន៍) របស់កម្ពុជា ទទួលបានប្រសិទ្ធភាព និងពង្រីកសក្តានុពលទូលំទូលាយ ក្នុងយុគសម័យបច្ចុប្បន្ន និងទៅអនាគត។ មិនតែប៉ុណ្ណោះ ក៏នឹងផ្តល់លទ្ធភាពច្រើនថែមទៀត ក្នុងការជំរុញ និងទាក់ទាញវិស័យវិទ្យាសាស្ត្រឱ្យមានការរីកចម្រើន និងជំរុញការផ្ទេរបច្ចេកវិទ្យា ស្របតាមបរិបទនៃបដិវត្តន៍ឧស្សាហកម្ម ជំនាន់ទី៤.០។

តាមរយៈការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នឹងធ្វើឱ្យកម្ពុជាមានស្ថាប័នមួយទទួលបន្ទុកច្បាស់លាស់ ជាក់លាក់ ***ជាលើកដំបូង*** ក្នុងការគ្រប់គ្រង និងអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការលើកទឹកចិត្តចំពោះរបកគំហើញថ្មីៗ (នវានុវត្តន៍)។ ម្យ៉ាងទៀត ក៏ជាជំហានកំណែទម្រង់មួយកម្រិតទៀត ដើម្បីធ្វើឱ្យវិស័យនេះ ផ្សារភ្ជាប់ទៅនឹងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ក៏ដូចជាពិភពលោក និងពង្រឹងបន្ថែមចំណុចខ្លាំងរបស់ខ្លួនលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដូចដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងបញ្ជាក់រួចហើយ នៅក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានលើកទី២៧ ក្រោមប្រធានបទ *«អាស៊ាន ៤.០ ៖ សហគ្រិនភាព និងបដិវត្តន៍ឧស្សាហកម្មលើកទី៤»* កាលពីខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងហាណូយ។

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជាពន្លឹក ចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** ដែលបានផ្តល់ការណែនាំ និងជួយសម្រួល ក្នុងការពិនិត្យ កែលម្អ សេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងអនុក្រឹត្យពាក់ព័ន្ធនឹងការរៀបចំក្រសួងថ្មី ហើយបានបង្កលក្ខណៈឱ្យមានការប្រជុំអន្តរក្រសួង និងក្រុមប្រឹក្សាអ្នកច្បាប់ពិនិត្យ ពិភាក្សាលើឯកសារគតិយុត្តនេះ បានឆាប់រហ័ស ទាន់ពេលវេលា។

ជាមួយនឹងការទទួលយកនូវការផ្លាស់ប្តូរចនាសម្ព័ន្ធថ្មីរបស់ក្រសួងនៅពេលនេះ, យើងខ្ញុំទាំងអស់គ្នាដែលជាអ្នកទទួលបន្ទុកអនុវត្ត បានប្រាកដក្នុងចិត្តថា នេះជាវិញ្ញាសាថ្មីមួយទៀតដែលត្រូវកែកពុន ពុះពារដោះស្រាយរាល់បញ្ហាប្រឈមនានាក្នុងរបត់ថ្មី។ ម្យ៉ាងវិញទៀត នេះក៏ជាបន្ទុកទទួលខុសត្រូវកាន់តែខ្ពស់ជាងមុន ដែលទាមទារឱ្យមន្ត្រីយើងខ្ញុំ កៀកស្មាគ្នា ឯកភាពគ្នា ប្រកបដោយឆន្ទៈមុតស្រួច និងមានមនសិកាវិជ្ជាជីវៈ ក្នុងការបំពេញបេសកកម្មថ្មីនេះ ដើម្បីឆ្លើយតបទៅនឹងទំនុកចិត្តរបស់ **សម្តេចតេជោ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា** ជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅ និងការជឿទុកចិត្តពីស្ថាប័ននីតិបញ្ញត្តិ។

- ***ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត*** *ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *អង្គសន្និបាតទាំងមូល ជាទីមេត្រី!*

ឆ្នាំ២០១៩ កន្លងទៅ គឺជារយៈពេលជាងមួយឆ្នាំនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលក្នុងនោះ មានការងារកំណែទម្រង់ជាច្រើន ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ជាពិសេស ការបន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ, កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ប្រព័ន្ធបៀវត្ស។ល។ ក្រោយរយៈពេលមួយឆ្នាំនៃការបង្កើតរាជរដ្ឋាភិបាល នីតិកាលទី៦ (គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩), ក្រសួងបានធ្វើរបាយការណ៍បូកសរុប វាយតម្លៃ អំពីសមិទ្ធផលនៃការអនុវត្តកម្មវិធីនយោបាយ និងលទ្ធផលកំណែទម្រង់ការងារ ជូនរាជរដ្ឋាភិបាលមួយជំហានរួចហើយ។ ប៉ុន្តែ សម្រាប់បំណាច់ឆ្នាំ២០១៩នេះ ក្រសួងបានរៀបចំជារបាយការណ៍ពិស្តារ និងសង្ខេប ដើម្បីដាក់ជូនអង្គសន្និបាតជ្រាប និងចូលរួមផ្តល់មតិបន្ថែម (ដូចមានឯកសារបោះពុម្ព (Hard Copy) និងឯកសារទន់ (Soft Copy) នៅក្នុងសំណុំឯកសារសន្និបាតដែលបានចែកជូនរួចហើយ។

ខ្ញុំបាទ សូមអនុញ្ញាតយកវេទិកានេះ គោរពរាយការណ៍ជូន **ឯកឧត្តមកិត្តិនីតិកោសល បណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងអង្គសន្និបាតទាំងមូល នូវចំណុចគោលៗមួយចំនួន អំពីវឌ្ឍនភាពនៃលទ្ធផលបំពេញភារកិច្ចតាមវិស័យជំនាញ ដូចខាងក្រោម៖

***១- វិស័យឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម៖***

- ក្នុងឆ្នាំ២០១៩ កន្លងទៅ ចំនួនរោងចក្រដែលបានបង្កើតថ្មីមានចំនួន ២៦៩រោងចក្រ កើនឡើងប្រមាណ ៥១% ធៀបនឹងឆ្នាំ២០១៨ ដែលចំនួនរោងចក្រកើតថ្មី មានតែ ១៧៨រោងចក្រ។ គិតមកដល់ពេលនេះ រោងចក្រដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានចំនួន ១.៧៣០រោងចក្រ ស្មើនឹង ១១៣% ធៀបនឹងឆ្នាំមុន ក្នុងនោះ ក៏មានលេចឡើងនូវឧស្សាហកម្មថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់ និងប្រើប្រាស់បច្ចេកវិទ្យាទំនើបជាងមុន ដូចជា រោងចក្រដំឡើងរថយន្ត ម៉ូតូ រោងចក្រផលិតគ្រឿងបន្លាស់ និងគ្រឿងបង្គុំយានយន្ត ម៉ូតូ គ្រឿងបង្គុំអេឡិចត្រូនិក បរិក្ខារអគ្គិសនី សម្ភារសំណង់ និងរោចក្រកែច្នៃកសិ-ឧស្សាហកម្ម ជាដើម។ល។ ដែលជាការកត់សម្គាល់ឃើញថា ផ្នែកទាំងនេះ កាលពីប្រាំឆ្នាំមុន មានចំនួនតិចតួចប៉ុណ្ណោះ។

- កម្លាំងពលកម្មបម្រើឱ្យផ្នែកឧស្សាហកម្ម ក៏មានការកើនឡើងប្រមាណ ៧% ធៀបនឹងឆ្នាំ ២០១៨ ក្នុងខណៈឧស្សាហកម្មកាត់ដេរ កាបូប និងស្បែកជើង កើន ៥% ហើយផ្នែកផ្សេងៗ កើនដល់ ២០%។ នេះជាការសបញ្ជាក់អំពីការវិវត្តន៍នៃវិស័យឧស្សាហកម្ម ដែលបានបង្កើតការងារថ្មី ក្រៅពីវិស័យកាត់ដេរសម្លៀកបំពាក់។

- តម្លៃសរុបបរិមាណផលិតផល មានចំនួន ១៤.៨៧៥លានដុល្លារ មានកំណើនស្របគ្នានឹងកំណើនរោងចក្រ ដោយមានកំណើន ១៣% ក្នុងនោះ ឧស្សាហកម្មនាំចេញផ្នែកផលិតផលសម្លៀកបំពាក់ កាបូប និងស្បែកជើង កើន ១១% និងឧស្សាហកម្មនាំចេញនៃផ្នែកផ្សេងទៀត កើន ២៧%។

- សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មកំពុងដំណើរការនៅក្រោមលក្ខខណ្ឌអនុគ្រោះជាងមុន តាមរយៈការដាក់ចេញគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូចនិងមធ្យម, ការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម និងការកែទម្រង់អត្រាការប្រាក់កម្ចីសម្រាប់វិស័យសហគ្រាសធុនតូចនិងមធ្យមជាដើម។ ទន្ទឹមនឹងនេះ ក្រសួងក៏បានលើកទឹកចិត្តដល់ការអនុវត្តការផ្ទេរមុខងារ និងការធ្វើប្រតិភូកម្មលើការគ្រប់គ្រងសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មដល់រដ្ឋបាលក្រុង ស្រុក និងរាជធានី ខេត្ត ដែលមកដល់ពេលនេះ កំពុងទទួលបានលទ្ធផលល្អ។ ចំណុចសេសសល់ដែលត្រូវបានកែលម្អ គឺការកាត់បន្ថយទម្រង់បែបបទនៃការស្នើសុំចុះបញ្ជី ឬបង្កើតសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលកំពុងទទួលបានការគាំទ្រពីអតិថិជនដែលជាអ្នកត្រូវការសេវារដ្ឋបាលពីរដ្ឋ។

- ចំនួនសហគ្រាសធុនតូច និងមធ្យមដែលបានចុះបញ្ជីផ្លូវការ មានចំនួន ៥២.១៥៤មូលដ្ឋាន ជាមួយនឹងចំនួនពលកម្មក្នុងវិស័យនេះ មានចំនួន ៨២៤.២៤៥នាក់ (ដោយមិនទាន់គិតដល់អ្នកបំពេញការងារដោយប្រយោល)។

- សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម ត្រូវបានតាក់តែងបញ្ចប់ និងត្រៀមឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅពេលខាងមុខ។

- ការធ្វើអធិការកិច្ច ដើម្បីពង្រឹងភាពអនុលោមតាមច្បាប់ និងបទដ្ឋានបច្ចេកទេស, ការពង្រឹងផ្នែកសុវត្ថិភាពរោងចក្រ សហគ្រាស នៅតែបន្តអនុវត្តតាមបែបភ្លៀងរលឹម ដោយបានចុះផ្ទាល់ចំនួន ៦០៧ រោងចក្រ សហគ្រាស។ ចំណុចវិជ្ជមានដែលគួរកត់សម្គាល់គឺ ម្ចាស់រោងចក្រ សហគ្រាស បានស្វាគមន៍ចំពោះការចុះធ្វើអធិការកិច្ចជាក្រុមចម្រុះគ្រប់ជំនាញ ដែលបានចុះជួយណែនាំ តម្រង់ទិស កែលម្អចំណុចខ្វះខាត ហើយដែលមិនមែនជាការទៅកោសរូស កៀបសង្កត់ម្ចាស់រោងចក្រ សហគ្រាស ដើម្បីលាភសក្ការៈរបស់អង្គភាព ឬបុគ្គលណាមួយឡើយ។ ជាទិសដៅបន្ត ក្រសួងនឹងចូលរួមជាមួយសមត្ថកិច្ចក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការចុះធ្វើអធិការកិច្ច ដើម្បីធ្វើឱ្យកាន់តែមានភាពងាយស្រួលដល់រោងចក្រ សហគ្រាសទាំងនោះ។

- បានបន្តជំរុញការអនុវត្តការងារកម្មសិទ្ធិឧស្សាហកម្ម ដោយក្នុងនោះ ពង្រីកភាពជាដៃគូក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសមួយចំនួន ដូចជា សឹង្ហបុរី (IPOS), ប្រទេសជប៉ុន (JPO), អង្គភាពកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (EPO) អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO), ស្ថាប័នកម្មសិទ្ធិបញ្ញាសាធារណរដ្ឋប្រជាមានិតចិន (CNIPA), ការិយាល័យកម្មសិទ្ធិបញ្ញាប្រទេសកូរ៉េ(KIPO)។ តាមរយៈនេះ ការទទួលសំណុំលិខិតស្នើសុំការផ្តល់ប្រកាសនីយបត្រតក្កកម្ម សរុបមានចំនួន ៣០៩សំណុំលិខិត កើនឡើងដល់ទៅ ៩៣% ធៀបនឹងឆ្នាំ២០១៨។

- បន្តយកចិត្តទុកដាក់ការបណ្តុះបណ្តាល អប់រំ ណែនាំវិធីសាស្ត្រក្នុងការជំរុញការបង្កើនផលិតភាពដល់ម្ចាស់សហគ្រាស សិប្បកម្មនានា និងស្ថាប័នពាក់ព័ន្ធ តាមវិធីសាស្ត្រអភិវឌ្ឍផលិតភាព «**ស៥**» ខាយហ្សិន (សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដារ ស្ថិតស្ថេរ) ដោយបានអនុវត្តចំនួន ៤៩គម្រោង និងមានអ្នកចូលរួមចំនួន ១.២៩៧នាក់។ គោលបំណងសំខាន់គឺ ដើម្បីជួយអភិវឌ្ឍក្រុមហ៊ុន សហគ្រាស លើផ្នែកប្រព័ន្ធគ្រប់គ្រងផលិតភាព, គុណភាព និងសុវត្ថិភាពផលិតផលម្ហូបអាហារ ដែលជាមូលដ្ឋាននៃការពង្រឹងបន្ថែមសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសទាំងនោះ។

- តាមរយៈអង្គភាពវាយតម្លៃទទួលស្គាល់ និងក្នុងក្របខណ្ឌ **"ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់"** ដែលជាយន្តការអន្តរក្រសួង, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានជំរុញការគ្រប់គ្រងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ និងមន្ទីរពិសោធន៍លើគ្រប់វិស័យ សំដៅពង្រឹងការអនុវត្តតាមគោលការណ៍ស្តង់ដារអន្តរជាតិដែលបានកំណត់ និងជួយគាំទ្រដល់សកម្មភាពប្រកួតប្រជែងលើទីផ្សារ ប្រកបដោយសមធម៌។

### ២- *វិស័យផ្គត់ផ្គង់ទឹកស្អាត៖*

- បានបន្តជំរុញការផលិតនិងផ្គត់ផ្គង់ទឹកស្អាត ទាំងផ្នែករដ្ឋ និងឯកជន សម្រេចបានបរិមាណជាលេខមូល គឺ ៣៤៧លានម៉ែត្រគូប កើនជាងឆ្នាំមុន ៣៨លានម៉ែត្រគូប ដែលមានចំនួនត្រឹម ៣០៩លានម៉ែត្រគូប ជាមួយនឹងអត្រាផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនក្នុងរង្វង់ ៥១% ប្រៀបនឹងតំបន់សេវាបច្ចុប្បន្ន។

- បានសម្រេចសម្ពោធសមិទ្ធផលថ្មីបន្ថែមទៀត ដែលការដាក់ឱ្យប្រើប្រាស់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មី នៅក្រុងកំពត និងក្រុងសៀមរាប។ បន្ថែមលើនេះ បានចាប់ផ្តើមដាក់ឱ្យអនុវត្តគម្រោងកសាងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មី នៅក្រុងស្ទឹងត្រែង ក្រោមហិរញ្ញប្បទានឥណទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងទឹកប្រាក់១០លានដុល្លារ ជាមួយនឹងសមត្ថភាព ១២.០០០ម៉ែត្រគូប/ថ្ងៃ ដែលបានខកខានការអនុវត្តជាងមួយឆ្នាំកន្លងទៅ ក្រោមការទន្ទឹងរង់ចាំរបស់ប្រជាជនយើងនៅទីនោះ។

- ក្រៅពីនេះ នៅមានគម្រោងថ្មីជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុនក្នុងការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតនៅខេត្តកំពង់ធំ ក្នុងទឹកប្រាក់ប្រមាណ ២៨,៥លានដុល្លារ សមត្ថភាព ៧.៥០០ម៉ែត្រគូប/ថ្ងៃ, ការពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តពោធិ៍សាត់ ក្នុងទឹកប្រាក់ប្រមាណ ២១,៨៦លានដុល្លារអាមេរិក សមត្ថភាព ៦.៦០០ម៣/ថ្ងៃ, គម្រោងហិរញ្ញប្បទានឥណទានសម្បទានរបស់ ADB និង AFD ក្នុងការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តបាត់ដំបង ក្នុងតម្លៃគម្រោងប្រមាណជាង ៣០លានដុល្លារអាមេរិក ជាមួយនឹងសមត្ថភាព៥០.០០០ម៣/ថ្ងៃ និងនៅខេត្តកំពង់ចាម ក្នុងវង្វង់ថវិកាប្រមាណ ១០លានដុល្លារអាមេរិក, សមត្ថភាព១១.០០០ម៣/ថ្ងៃ, គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន ដែលប្រើប្រាស់ថវិកាប្រមាណ ៣១,៣លានដុល្លារអាមេរិក, សមត្ថភាព ៣០.០០០ម៣/ថ្ងៃ គឺទាំងអស់នេះ ពិតជាបានរួមចំណែកជួយដោះស្រាយបញ្ហាប្រឈមចំពោះកង្វះទឹកស្អាតរបស់ប្រជាជនយើង និងសម្រាប់បម្រើដល់ផ្នែកផលិកម្មនានា។

- ក្រៅពីនេះ ក្រសួងកំពុងអនុវត្តយុទ្ធសាស្ត្រលើកទឹកចិត្តដល់ផ្នែកឯកជនក្នុង និងក្រៅប្រទេសក្នុងការវិនិយោគបន្ថែមទៅលើការសាងសង់រោងចក្រទឹកស្អាតនៅតំបន់ដទៃទៀត ដោយរូបភាពលក់ទឹកដុំជូនដល់អង្គភាពរដ្ឋាករទឹករដ្ឋ និងអាជីកម្មទឹកស្អាតឯកជន, ឬការចូលរួមវិនិយោគលើការពង្រីកសមត្ថភាព និងការផ្លាស់ប្តូរបច្ចេកវិទ្យាក្នុងផលិតកម្មទឹកស្អាតឯកជន ឬជាការវិនិយោគដោយផ្ទាល់សម្រាប់បំពេញបន្ថែមការផ្គត់ផ្គង់ទឹកដល់ប្រជាពលរដ្ឋនៅតាមតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកផ្ទៃសេវានៃការផ្គត់ផ្គង់ទឹកស្អាតឱ្យមានវិសាលភាពធំឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

- យោងតាមស្មារតីសន្និបាតរបស់ក្រសួងកាលពីដើមឆ្នាំមុន, ក្រសួងនឹងបន្តអនុវត្តវិធានការមុតស្រួចជាងមុនក្នុងការអនុវត្តលក្ខខណ្ឌដែលមានចែងក្នុងប្រកាសអនុញ្ញាត និងបទដ្ឋានគតិយុត្ត ដោយក្នុងនោះ សង្កត់ធ្ងន់លើបញ្ហាអ្នកដែលធ្វើអាជីវកម្មមិនមានការអនុញ្ញាតត្រឹមត្រូវ, អ្នកមានប្រកាសអនុញ្ញាតរួចហើយ តែមិនអនុវត្តការពង្រីកការផ្គត់ផ្គង់តាមផែនការកំណត់ ឬរំលោភលើតំបន់សេវាអ្នកដទៃ ឬមិនអនុវត្តតាមគោលការណ៍ថ្លៃលក់ទឹកស្អាតឱ្យបានត្រឹមត្រូវ ឬមិនអនុលោមតាមគុណភាពទឹកស្អាត។ អ្នកដែលមិនអនុលោមតាមបទប្បញ្ញត្តិនៃប្រកាស និងបទដ្ឋានបច្ចេកទេស នឹងប្រឈមក្នុងការដកសិទ្ធិធ្វើអាជីវកម្មមកវិញដោយគ្មានការបន្ធូរបន្ថយទៀតទេ។

### *៣- ការអភិវឌ្ឍវិស័យស្តង់ដារ*

- ឆ្នាំនេះ ក៏ដូចឆ្នាំកន្លងទៅ **ក្រុមប្រឹក្សាស្តង់ដារជាតិ**ដែលជាយន្តការអន្តរក្រសួង បានជំរុញការពិនិត្យ ស្រាវជ្រាវ និងបានដំណើរការប្រជុំអនុម័តស្តង់ដារផលិតផល សម្រាប់ការផ្សព្វផ្សាយដាក់ឱ្យអនុវត្តបានចំនួន ៣១ស្តង់ដារបន្ថែមទៀត, ធ្វើឱ្យចំនួនស្តង់ដារដែលកំពុងដាក់ឱ្យប្រើប្រាស់បច្ចុប្បន្នមានដល់ ៩២៦ស្តង់ដារផលិតផល ដែលកាលពីត្រឹមឆ្នាំ២០១៥ មានចំនួនតែ ៤០៤ស្តង់ដារ។ ប្រការនេះ បានជួយដល់ការពង្រឹងសក្តានុភាពនៃផលិតផលកម្ពុជា និងការធ្វើពិពិធកម្មទីផ្សារផលិតផលកម្ពុជា។

- ក្រៅពីនេះ សមត្ថភាពមជ្ឈមណ្ឌលមន្ទីរពិសោធន៍កម្ពុជា ក៏បានក្លាយជាអង្គភាពសេនាធិការមួយដែលមានកម្រិតអន្តរជាតិ អនុលោមតាមស្តង់ដារ ISO/IEC 17025 ដែលអាចជឿទុកចិត្តបានសម្រាប់អ្នកប្រកបធុរកិច្ច និងសាធារណជន លើការធ្វើតេស្ត វិភាគគុណភាពផលិតផលរហូតដល់ជាង៤០ប៉ារ៉ាម៉ែត្រ

ហើយបានធ្វើការត្រួតពិនិត្យគុណភាព និងធ្វើតេស្ត វិភាគគំរូផលិតផលបានដល់ ៨.៤៤៦គំរូផលិតផល កើនលើសឆ្នាំមុនដល់ទៅ ១.៤២១គំរូផលិតផល។ កិច្ចប្រឹងប្រែងនេះ បានឆ្លើយតបទៅនឹងសេចក្តីត្រូវការបញ្ជាក់គុណភាពទំនិញរបស់អតិថិជន និងជាកត្តាលើកកម្ពស់ភាពប្រកួតប្រជែងរបស់ផលិតផលកម្ពុជា។ ទន្ទឹមនឹងនេះ ក្រសួងបានបំពាក់បន្ថែមឧបករណ៍មន្ទីរពិសោធន៍ចល័តជូនដល់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ដែលកាន់តែធ្វើឱ្យអង្គភាពនេះ មានលទ្ធភាពបំពេញភារកិច្ចជំនាញនៅតាមមូលដ្ឋានជិតឆ្ងាយ ឬចុះជួយអន្តរាគមន៍ពេលមានបាតុភាពសង្ស័យថា មានការពុលចំណីអាហារនៅកន្លែងខ្លះទៅតាមការចាំបាច់។

### *៤- ការងារមាត្រាសាស្ត្រ៖*

- ការងារមាត្រាសាស្ត្រ ជាសេវាកម្មគាំទ្រ និងបំពេញឱ្យគ្នាទៅវិញទៅមកជាមួយវិស័យជំនាញដទៃទៀតរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងកំពុងដើរតួនាទីសំខាន់ក្នុងការរួមចំណែកធ្វើឱ្យមានសុខដុមនីយកម្មក្នុងសកម្មភាពពាណិជ្ជកម្ម សុខភាព សុវត្ថិភាព និងបរិស្ថានធុរកិច្ច។ ក្នុងឆ្នាំកន្លងទៅ ការងារមាត្រាសាស្ត្របានពង្រីកវិសាលភាពនៃការពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម ធ្វើតេស្តវិភាគ និងអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម និងសេវាកម្ម។ វឌ្ឍនភាពក្នុងវិស័យនេះ បានបង្ហាញឡើងតាមរយៈការបង្កើនកិច្ចការព្យាសកម្មឧបករណ៍មាត្រាសាស្ត្រដល់ចំនួន ១.០១០គ្រឿង ដែលឆ្នាំមុននេះ សម្រេចបានត្រឹមចំនួន ៦៤៦គ្រឿងប៉ុណ្ណោះ។ បានត្រួតពិនិត្យជញ្ជីងតោនបានចំនួន ១៦១គ្រឿង ដែលបញ្ហានេះ ក៏មានការពាក់ព័ន្ធដល់ការធ្វើអាជីវកម្មទិញ-លក់ផលិតផលកសិកម្មរបស់ប្រជាជនយើង។
- នៅថ្នាក់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត បានបង្កើនការអនុវត្តភារកិច្ចពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្របានច្រើនជាងមុន ដោយកើនពី ១៨.៤២៨ ក្នុងឆ្នាំ២០១៨ ដល់ចំនួន ២៥.៦៧០លើឧបករណ៍វង្វាស់វង្វាល់ ជាពិសេសលើដៃបាញ់ប្រេងតាមស្ថានីយប្រេង ដែលមានចំនួនដល់ទៅ ២៤.៤៧៩។ ក្រៅពីនេះ នៅតាមផ្សារទីប្រជុំជនធំៗ មន្ទីរបានដាក់ឱ្យប្រើប្រាស់នូវជញ្ជីងយុត្តិធម៌ ដែលជួយដល់ការពង្រឹងភាពត្រឹមត្រូវសម្រាប់អាជីវកម្មទិញលក់ទំនិញ និងអតិថិជននៅលើទីផ្សារ។

### ***៥- ការគ្រប់គ្រង ដឹកនាំស្ថាប័ន និងអភិបាលកិច្ច***

- អនុវត្តតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងបានពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើការពិនិត្យ និងស្នើកែសម្រួលមួយជំហានទៀតនូវកម្រងសេវាសាធារណៈ។ នៅក្នុងនេះ ចំណុចខ្លះយើងនឹងលុបចោលប្រភេទសេវាខ្លះដែលមិនចាំបាច់ និងកាត់បន្ថយបែបបទរដ្ឋបាលខ្លះទៀតក្នុងការស្នើសុំចុះបញ្ជី ការបង្កើតសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។ ព្រមជាមួយគ្នានេះ បានចូលរួមផ្តល់មតិកែលម្អនៅក្នុងកម្មវិធីពិនិត្យកម្រងសេវារដ្ឋបាលនៅលើទូរស័ព្ទដៃ ដែលដាក់ឱ្យអនុវត្តដោយក្រសួងមុខងារសាធារណៈ។ ក្នុងការផ្តល់សេវាសាធារណៈ ក្រសួងបានបំផុសស្មារតី និងឆន្ទៈអនុវត្តយ៉ាងម៉ឺងម៉ាត់នូវអនុសាសន៍ណែនាំដ៏មានតម្លៃរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺឱតខំ «***ធ្វើឱ្យលឿន ធ្វើឱ្យបាន និងធ្វើដោយតម្លាភាព***»។
- បន្តយកចិត្តទុកដាក់គាំទ្រ និងអភិវឌ្ឍន៍វិស័យឯកជន ដោយបានចាត់បញ្ជូនថ្នាក់ដឹកនាំជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ចូលរួមក្នុងក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យ

ឯកជន ដែលមានចំនួន ១៣ក្រុមការងារ ពាក់ព័ន្ធនឹងផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម, ផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា, ផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច និង១០ផ្នែកផ្សេងទៀត។ ក្រុមការងារតាមវិស័យទាំងនេះ បានប្រជុំពិនិត្យ ពិភាក្សាលើបញ្ហាប្រឈម ឬកង្វល់នានា ដើម្បីរួមគ្នារិះរកវិធានការដោះស្រាយ និងលើកមតិជូនរាជរដ្ឋាភិបាលដើម្បីដោះស្រាយ ក្នុងគោលដៅជួយសម្រួល និងបង្កលក្ខណៈដល់វិស័យឯកជនក្នុងការប្រកបពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម និងរក្សាបាននូវភាពទាក់ទាញការវិនិយោគនៅកម្ពុជា។ នៅក្នុងផ្ទៃក្នុងក្រសួង និងរាល់ពេលចុះបំពេញបេសកកម្មនៅតាមខេត្ត, ខ្ញុំបាទតែងប្រកាសជំហររបស់ក្រសួង គឺត្រូវជួយឱ្យផ្នែកឯកជន ***គេឈររឹងប៉ឹងបាន ដើរបាន រីកចម្រើនបាន*** ដើម្បីជាកម្លាំងចន្ទល់ទ្រទ្រង់សេដ្ឋកិច្ចជាតិ ហើយចៀសវាងអនុវត្តវិធានការ «***ប៉ះដៃយកដៃ-ប៉ះជើងយកជើង***»។

- ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំពុងត្រូវបានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ បញ្ហាចម្បងសម្រាប់ដំណាក់កាលថ្មីនេះ គឺការអនុវត្តថវិកាតាមកម្មវិធី ដែលផ្សារភ្ជាប់គ្នានឹងសម្មតិកម្មនៃលទ្ធផលអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព។ បរិបទនេះ ទាមទារឱ្យមានការកែប្រែរបៀបធ្វើការនៅតាមអង្គភាពដែលត្រូវមានសូចនាករវាស់វែងច្បាស់លាស់ និងមានការពិនិត្យវាយតម្លៃលើលទ្ធផលអនុវត្តតាមចង្កោមសកម្មភាពទាំងនោះ។ ក្រៅពីនេះ ក្រសួងនៅបន្តកៀរចំណូលបង់ចូលថវិកា ដោយសម្រេចបានការបង់ចំណូលចូលថវិកាជាតិជាង ១៩៣ពាន់លានរៀល។

- ក្នុងការជំរុញឱ្យគ្រប់អង្គភាព គ្រប់ថ្នាក់សម្រេចបានលទ្ធផលការងាររបស់ខ្លួន មិនអាចមើលរំលងការងារបណ្ដុះបណ្ដាលជួរមន្ត្រីរាជការបានទេ។ ក្នុងន័យនេះ ក្រសួងបានបន្តផ្ដោតការយកចិត្តទុកដាក់ដល់ការបណ្ដុះបណ្ដាល បង្កើនសមត្ថភាពមន្ត្រី បានចំនួន ៤៧៨រូប (បណ្ដុះបណ្ដាលក្នុងប្រទេសចំនួន ២១៥រូប និងនៅក្រៅប្រទេសចំនួន ២៦៣រូប)។

- ជាមួយគ្នានេះ ការធ្វើសវនកម្ម និងអធិការកិច្ចការងារផ្ទៃក្នុងក្រសួង ដើម្បីកែលម្អ និងពង្រឹងការអនុវត្តគោលការណ៍ណែនាំ, ការគ្រប់គ្រងចាត់ចែងមន្ត្រី, ការគ្រប់គ្រងនិងចាត់ចែងថវិកា ទ្រព្យសម្បត្តិរដ្ឋក៏ត្រូវបានអនុវត្តជាប្រចាំ និងបានចាត់វិធានការចេញជាលិខិតណែនាំ ឱ្យកែតម្រូវជាបន្តបន្ទាប់ នៅពេលរកឃើញថាមានការអនុវត្តខុសឆ្គង ឬធកល្វែង។ មានករណីខ្លះ ត្រូវបានឈានដល់ការអនុវត្តវិន័យមន្ត្រីរាជការដោយការផ្ទេរចេញ ឬបញ្ចប់មុខតំណែងមន្ត្រីដែលមានកំហុសដដែលៗនោះទៀតផង។

- ក្រៅពីនេះ បានចាត់មន្ត្រីដែលស្ថិតក្នុងមុខតំណែងចាប់ពីថ្នាក់អគ្គនាយករងឡើងទៅចំនួន **៨១រូប** ឱ្យចូលរួមក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត (ដោយឡែក ខេត្តកំពត, រូបខ្ញុំបាទទទួលដឹកនាំផ្ទាល់ជា ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តនោះ) ដើម្បីចូលរួមចុះធ្វើវេទិកាសាធារណៈ ទទួលស្ដាប់បញ្ហាកង្វល់ សំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ ឬអាជីវករ សេវាករ។ បន្ថែមលើនេះក៏បានចាត់តាំងបំពេញបន្ថែមមន្ត្រីក្រសួងចំនួន **២២រូប**ផ្សេងទៀត ចូលរួមក្រុមការងាររាជរដ្ឋាភិបាល នៅដើមឆ្នាំនេះផងដែរ។ តាមរយៈតំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលចុះបេសកកម្មនៅតាមមូលដ្ឋាន, បញ្ហាសំណូមពរនានារបស់ប្រជាពលរដ្ឋ ឬទំនាស់ផ្សេងៗ ត្រូវបានឆ្លើយតបនៅហ្នឹងកន្លែង ឬពាំនាំយកមកជូនក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យជួយដោះស្រាយ។ ម៉្យាងទៀត ក្រុមការងាររាជរដ្ឋាភិបាល ក៏បានចូលរួមពិនិត្យដោះស្រាយទំនាស់ផ្សេងៗ, ពង្រឹងប្រសិទ្ធភាពការងារនៅមូលដ្ឋានក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ និងផ្សព្វផ្សាយគោលនយោបាយនិងសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល។

- ដោយឡែក ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ក្រសួង ក៏ត្រូវបានកសាង និងជួសជុលកែលម្អជាបន្តបន្ទាប់ មានដូចជា អគារទីស្តីការថ្មីកម្ពស់ ១៨ជាន់ និងអគារថ្មី នៃមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជាចំនួន ២អគារ ក៏កំពុងដំណើរការសាងសង់ និងសំណង់មួយចំនួនទៀតនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ក៏ដូចជាអគារធ្វើការនៃច្រកចេញចូលតែមួយ។ល។ ក៏ត្រូវបានកែលម្អ។ ដោយសារមានលក្ខណៈសម្បត្តិបែបនេះ, ខ្ញុំគិតថា នៅពេលមានការរៀបចំក្រសួងថ្មី (ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍-MISTI) ប្រហែលជាអាចជួយដោះស្រាយកន្លែងធ្វើការ សម្រាប់អង្គភាពថ្នាក់អគ្គនាយកដ្ឋានចំនួនពីរ ដែលនឹងគ្រោងនឹងបង្កើតឡើងតាមការសម្រេចរបស់រាជរដ្ឋាភិបាល នៅសល់តែបញ្ហាធនធានមនុស្សដែលយើងនៅជួបការលំបាកច្រើននៅឡើយ។

- ***ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!***
- *ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី!*

ជាការពិត ពេលវេលាពិតជាមិនអនុញ្ញាតឱ្យខ្ញុំបាទជម្រាបបញ្ជាក់ជូនអស់សេចក្តី ជូនគណៈអធិបតី និងអង្គសន្និបាត នូវកិច្ចការដែលក្រសួងសម្រេចបាន, បញ្ហាសេសសល់ និងទិសដៅដែលនឹងត្រូវអនុវត្តបន្តក្នុងពេលនេះទេ។ ប៉ុន្តែ ខ្ញុំបាទសង្ឃឹមថា ចំណុចជាគោលៗខាងលើ នឹងជាជំនួយស្មារតីមួយ សម្រាប់ការពិចារណា ការវិភាគវាយតម្លៃ និងការផ្តល់ធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ, ហើយនៅពេលបន្ទាប់ពីកម្មវិធីបើកអង្គសន្និបាត, ខ្ញុំបាទនឹងមានឱកាសបានស្តាប់ការចូលរួមផ្តល់យោបល់ពីវាគ្មិនទាំងអស់។

មុននឹងបញ្ចប់ ខ្ញុំបាទសូមជំនួសមុខអង្គសន្និបាតទាំងមូល សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ,** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, ដែលតែងបានគាំទ្រ និងបង្កលទ្ធភាពងាយស្រួលដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ខ្ញុំបាទសង្ឃឹមថា នៅពេលខាងមុខ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏នៅតែទទួលបានការជួយឧបត្ថម្ភ គាំទ្រ និងការលើកទឹកចិត្តបន្ថែមទៀតពី **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ**។ យើងខ្ញុំទាំងអស់គ្នា នឹងត្រងត្រាប់ស្តាប់ដោយយកចិត្តទុកដាក់ នូវសុន្ទរកថាគន្លឹះ រួមទាំងអនុសាសន៍ណែនាំល្អៗរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ, រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** នាពេលបន្តិចទៀត ដើម្បីធ្វើជាមាគ៌ាតម្រង់ទិស សម្រាប់យើងខ្ញុំទាំងអស់គ្នាអនុវត្ត និងជំរុញឱ្យមានល្បឿនអភិវឌ្ឍន៍ រីកចម្រើនទៅមុខថែមទៀត។

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទគ្រប់លំដាប់ថ្នាក់, ខ្ញុំបាទសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំចាស់ និងឆ្នាំថ្មី សូមជួយប្រោះព្រំប្រសិទ្ធពរជ័យ វិបុលសុខ ជូនចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** និង **លោកជំទាវ** ព្រមទាំងកូនៗចៅៗ សូមទទួលបាននូវសិរីសួស្តី ជ័យមង្គល សេចក្តីសុខចម្រើនជារៀងដរាប និង សូមមានសុខភាពល្អមាំមួនប្រាជ្ញាវាងវៃ ដើម្បីបន្តចូលរួមជាមួយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដឹកនាំ និងបម្រើប្រទេសជាតិប្រជាពលរដ្ឋក្នុងសុខសន្តិភាព សុខដុមរមនា និងសុភមង្គល ជាមួយនឹងការអភិវឌ្ឍរីកចម្រើនជឿនលឿនរឹងមាំ ជាលំដាប់។

ខ្ញុំបាទសូមថ្លែងនូវការអរគុណចំពោះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូជាតិ អន្តរជាតិ វិស័យឯកជន និងផ្នែកពាក់ព័ន្ធដទៃទៀត ដែលមានឆន្ទៈខ្ពស់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាដៃគូល្អជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជួយគាំទ្រក្រសួងក្នុងការបំពេញបេសកកម្មបម្រើរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ឱ្យសម្រេចបាននូវសមិទ្ធផលជាផ្លែផ្កាជាច្រើន។ ខ្ញុំបាទសូមសំណូមពរដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ រួមនិងវិស័យឯកជន, សូមបន្តជួយពូនជ្រុំ ឧបត្ថម្ភគាំទ្រ និងសហការជិតស្និទ្ធជាមួយក្រសួងដែលគ្រោងបង្កើតថ្មី គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យមានដំណើរការល្អ និងជោគជ័យ។

ក្នុងឱកាសត្រៀមទទួលស្វាគមន៍ឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំជូត ព.ស.២៥៦៤ ដែលនឹងខិតមកដល់នាពេលខាងមុខ ជាមួយនឹងការប្រារព្ធបើកសន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារឆ្នាំ២០២០, ខ្ញុំបាទសូមគោរពជូនពរគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ សមាជិក សមាជិកា នៃអង្គសន្និបាតទាំងអស់ សូមជួបប្រទះតែនឹងពុទ្ធពរប្រាំប្រការ គឺ ***អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ*** កុំបីឃ្លៀងឃ្លាតឡើយ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់, ជំនួសមុខឱ្យអង្គសន្និបាតទាំងមូល ខ្ញុំបាទសូមអនុញ្ញាតគោរពអញ្ជើញ **ឯកឧត្តមអភិសន្តិបណ្ឌិត** ... 

**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងជា **តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ**ព្រះរាជាណាចក្រកម្ពុជា** សូមអញ្ជើញថ្លែងសុន្ទរកថាបើកសន្និបាត និងផ្តល់អនុសាសន៍ណែនាំដល់អង្គសន្និបាត។

***សូមគោរពអញ្ជើញ និងសូមគោរពអរគុណ!***